# សេចក្តីថ្លែងការណ៍

# ស្តីពី

# ស្នើលុបចោលការកំណត់ឱ្យបេក្ខជនប្រឡងក្របខ័ណ្ឌ
# មន្ត្រីរាជការត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានពីរដូសជាមុន

*រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០២១*

សមាគម សហជីព អង្គការសង្គមស៊ីវិល មានកង្វល់យ៉ាងខ្លាំងចំពោះសេចក្តីជូនដំណឹងរបស់ក្រសួងមុខងារសាធារណៈ លេខ១៧៨៣ មស.សជណ បានតម្រូវឱ្យបេក្ខជនដែលបានដាក់ពាក្យស្នើសុំសិទ្ធិប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ន ចំនួន៦ រួមមាន ក្រសួងមុខងារសាធារណៈ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋលេខាធិកាដ្ឋានអាកាសចរស៊ីវិល ត្រូវចាក់វ៉ាក់សាំងចំនួនពីរដងរួចរាល់ជាមុនសិន។ ចំពោះបេក្ខជនណាដែលមិនបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឬគ្មានលិខិតបញ្ជាក់ពីករណីដែលពុំអាចចាក់វ៉ាក់សាំងបានពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត នឹងពុំអនុញ្ញាតឱ្យបេក្ខជនរូបនោះចូលរួមប្រឡងឡើយ។

សេចក្តីកំហិតនេះ ធ្វើឡើងស្របពេលរាជរដ្ឋាភិបាលកម្ពុជាមិនទាន់មានលទ្ធភាពផ្តល់នូវ វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់ប្រជាពលរដ្ឋតាមផែនការកំណត់នៅឡើយ។ គិតត្រឹមថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០២១នេះ ប្រទេសកម្ពុជាទើបទទួលបានវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចំនួន ៤,០២៤,០០០ដូស ហើយបានចាក់ជូនប្រជាពលរដ្ឋ ចំនួន ១,៨៩៩,៩៨៨នាក់[1] តាមគោលការណ៍ស្ម័គ្រចិត្ត។ ក្នុងចំណោមប្រជាពលរដ្ឋដែលទទួលបានវ៉ាក់សាំងទាំងអស់ មានប្រជាពលរដ្ឋប្រមាណត្រឹមតែ ១,១១៧,២៨០នាក់បានចាក់វ៉ាក់សាំងចំនួន០២ដូសរួចរាល់  ក្នុងចំណោមអ្នកបានទទួលចាក់វ៉ាក់សាំងចំនួន នៃប្រជាពលរដ្ឋកម្ពុជាសរុបប្រមាណ ១៥,២៨៨,៤៨៩ នាក់[2]។ ដូច្នេះ ប្រជាពលរដ្ឋកម្ពុជា ប្រមាណជាង១៣.៣លាននាក់ផ្សេងទៀតពុំទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩នៅឡើយទេ។ តាមផែនការរបស់រាជរដ្ឋាភិបាលអំពីដំណើរនៃការផ្តល់ជូនវ៉ាក់សាំងដល់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបាន និងកំពុងផ្តល់អាទិភាពខ្ពស់ក្នុងការចាក់វ៉ាក់សាំងដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់ក្រហម និងលឿងទុំនៃភូមិសាស្ត្របិទខ្ទប់ និង

---

[1] របាយការណ៍របស់ក្រសួងសុខាភិបាល ចាប់ពី ១០ កុម្ភៈ ដល់ ១០ ឧសភា ២០២១

[2] របាយការណ៍ជំរឿនប្រជាសាស្ត្រ ឆ្នាំ២០១៩

តំបន់មានហានិភ័យខ្ពស់ផ្សេងទៀតតាមគោលការណ៍ស្ម័គ្រចិត្តតែប៉ុណ្ណោះ។ ការណ៍នេះមានន័យថា ប្រជាពលរដ្ឋដែលមិនកំពុងរស់នៅក្នុងតំបន់អាទិភាពខ្ពស់ នឹងជួបការលំបាកក្នុងការទទួលបានការចាក់វ៉ាក់សាំងតាមការកំហិតរបស់ក្រសួងខាងលើ។

យោងតាមខ្លឹមសារនៃសេចក្តីជូនដំណឹងខាងលើរបស់ក្រសួងមុខងារសាធារណៈនេះ អាចបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្នុងដំណើការជ្រើសរើសធនធានមនុស្សឱ្យបានចូលរួមប្រកួតប្រជែងប្រកបដោយសេរីភាព តម្លាភាព សមភាព គណនេយ្យភាព យុត្តិធម៌ និងផ្ទុយពីរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលបានចែងពីភាពស្មើគ្នាចំពោះមុខច្បាប់ត្រង់មាត្រា ៣១ និងមាត្រា ៣៦ ត្រង់កឋាខ័ណ្ឌទីមួយដែលបានចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ សម្រាប់ការជ្រើសរើសមុខរបរស្របតាមសមត្ថភាពខ្លួន។

ការកំហិតដូចមានចែងក្នុងលិខិតជូនដំណឹងនេះ បង្កជាការលំបាកដល់បេក្ខជន អាចធ្វើឱ្យការប្រកួតប្រជែងពុំមានតម្លាភាព ប្រសិទ្ធិភាព យុត្តិធម៌ និងបង្កើតឱ្យមានវិប្បដិសារី ដោយសារបេក្ខជនដែលមានសមត្ថភាពពិតប្រាកដ តែពុំបានចាក់វ៉ាក់សាំងតាមចំនួនកំណត់ក៏ត្រូវបានបាត់សិទ្ធិក្នុងការចូលរួមប្រឡង។ ហេតុនេះ នឹងធ្វើឱ្យយុវជនមានសមត្ថភាពបាត់បង់ឱកាសចូលរួមប្រកួតប្រជែង ដើម្បីក្លាយជាមន្ត្រីរាជការបំពេញកិច្ចការសាធារណៈ ជាមួយគ្នានេះស្ថាប័នរដ្ឋក៏បាត់បង់ឱកាសក្នុងការទទួលបានធនធានមនុស្សប្រកដោយគុណភាពសម្រាប់ចូលរួមពង្រឹងសេវាសាធារណៈ និងអភិវឌ្ឍន៍សង្គមជាតិ។

យើងទាំងអស់គ្នាដែលជាសមាគម សហជីព អង្គការសង្គមស៊ីវិល និងសហគមន៍ ដែលមានរាយនាមដូចខាងក្រោម ស្នើសុំឱ្យរាជរដ្ឋាភិបាលលុបចោលនូវលក្ខខណ្ឌកំណត់ឱ្យបេក្ខជនប្រឡងចូលក្របខ័ណ្ឌ  មន្ត្រីរាជការ ត្រូវចាក់វ៉ាកសាំងឱ្យបានពីរដូសជាមុនសិននេះ ដើម្បីបង្កើតបរិយាកាសប្រកួតប្រជែងប្រកបដោយបរិយាប័ន្ន។

*ទំនាក់ទំនងសាកសួរព័ត៌មានបន្ថែម៖*


- **លោកបណ្ឌិត ប៉ា ចន្ទរឿន** 012 766 364
  ប្រធានវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា
- **លោក អ៊ុល វ៉ាន់** 093 913 011
  ប្រធានសមាគមបណ្តាញយុវជនកម្ពុជា
- **លោក ទឹម ម៉ាឡែ** 017 990 689
  ប្រធានសមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា

*ស្ថាប័នគាំទ្រសេចក្តីថ្លែងការណ៍៖*

\`

១. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
២. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព (PDP-Center)
៣. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
៤. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៥. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៦. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
៧. សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA)
៨. សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
៩. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
១០. សហភាពផ្ទះសាមគ្គី (SH)
១១. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១២. ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)
១៣. សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC-Cambodia)
១៤. អង្គការកម្មវិធិអភិវឌ្ឍន៍ធនធានយុវជន (YRDP)
១៥. អង្គការសមធម៌កម្ពុជា (EC)
១៦. អង្គការយុវជនសន្តិភាព (YFP)
១៧. ក្លឹបមិត្តអ្នកអានសៀវភៅ (FRC)
១៨. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ (LRSU)
១៩. សហព័ន្ធសហជីពជាតិ នៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា (NIFTUC)
២០. អង្គការសមាគមជាងឆ្នោត (STT)
២១. សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (LICADHO)